# សុវត្ថិភាពជាចម្បង

## សម្រាប់អ្នកដំណើរជាសិស្សានុសិស្ស

មិនថាអ្នកកំពុងធ្វើដំណើរទៅសាលារៀន ទៅហ្វឹកហាត់កីឡា ឬទៅធ្វើសកម្មភាពសិស្សានុសិស្សទេ រាល់ការបើកបររថយន្តគ្រួសារសុទ្ធតែមានសារៈសំខាន់ នៅពេលគិតអំពីសុវត្ថិភាព។ គ្រោះថ្នាក់ចរាចរណ៍គឺជាមូលហេតុចម្បងមួយដែលបណ្តាលឱ្យកុមារស្លាប់នៅសហរដ្ឋអាមេរិក ប៉ុន្តែការស្លាប់ទាំងនេះអាចទប់ស្កាត់បាន។[1] ការអនុវត្តតាមជំហានសុវត្ថិភាពសាមញ្ញៗអាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងក្នុងការការពារអ្នកដំណើរ។

## ដឹងពីចំណុចខ្វាក់របស់អ្នក

គ្រប់យានយន្តមានចំណុចខ្វាក់ ដែលជាតំបន់នៅខាងក្រៅយានយន្តដែលអ្នកបើកបរមើលមិនឃើញ សូម្បីតែមានកញ្ចក់រថយន្ត និងកាមេរ៉ាមើលក្រោយក៏ដោយ។ ចំណុចខ្វាក់នៅរថយន្ត SUV និងឡានក្រុងសាលាមានលក្ខណៈធំ និងអាចបាំងសិស្សបានយ៉ាងងាយស្រួល។ ត្រូវពិនិត្យមើលជានិច្ចមុនពេលបួរចេញពីកន្លែង “ចត” ថយក្រោយ និងពេលបួរគន្លងផ្លូវ។

## ស្គាល់ច្បាប់ចរាចរណ៍ផ្លូវគោក

អ្នកបើកបរដែលមានចំណេះដឹងគ្រប់គ្រាន់ គឺជាអ្នកបើកបរដែលមានសុវត្ថិភាព។ ឈ្វេងយល់ដោយខ្លួនឯងអំពីនីតិវិធីមកដល់ និងចេញពីសាលារៀនរបស់អ្នក និងយល់អំពីវិធានស្តីពីតំបន់សាលារៀន៖

- **ប្រើប្រាស់កៅអីរថយន្តឱ្យបានត្រឹមត្រូវ** - កុមារដែលមានអាយុក្រោមប្រាំបីឆ្នាំ និងកម្ពស់ក្រោម 57 អ៊ីញ ត្រូវតែអង្គុយក្នុងកៅអីរថយន្ត ឬកៅអីបន្ថែមដែលត្រូវបានអនុម័តដោយសហព័ន្ធ។[2]
- **អ្នកគ្រប់គ្នាត្រូវពាក់ខ្សែក្រវ៉ាត់** - នេះជាច្បាប់នៅរដ្ឋ Massachusetts។[3]
- **បន្ថយល្បឿននៅក្នុងតំបន់សាលារៀន** - ល្បឿនអតិបរមា 20 ម៉ាយក្នុងមួយម៉ោង (MPH) គឺជាល្បឿនអតិបរមានៅក្នុងតំបន់សាលារៀន។[4]
- **កុំវ៉ាជែងឡានក្រុងសាលាដែលបើកភ្លើងភ្លឹបភ្លែតៗ** - ឥឡូវនេះ កាមេរ៉ាដៃនៅចំណតឡានក្រុងត្រូវបានអនុញ្ញាតឱ្យជួយតាមដានអ្នករំលោភបំពាន។[5]
- **កុំឈប់នៅមួយកន្លែង** – ការឈប់នៅមួយកន្លែងលើស 5 នាទីគឺខុសនឹងច្បាប់។[6]
- **អនុវត្តតាមផ្លាកសញ្ញាដែលបានបិទផ្សាយ** - កុំចតនៅកន្លែងដែលផ្លាកសញ្ញាសរសេរថា “ហាមចត” “ចំណតសម្រាប់តែជនពិការ” និង “ផ្លូវសម្រាប់ពន្លត់អគ្គីភ័យ”។





ប្រភព៖

1 www.cdc.gov/child-passenger-safety/about/index.html
2 www. mass.gov/info-details/car-seat-laws-in-massachusetts
3 www.mass.gov/info-details/car-seat-laws-in-massachusetts
4 www.malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section17
5 www. mass.gov/info-details/mass-general-laws-c90-ss-14c
6 www. malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section16B


massDOT
Massachusetts Department of Transportation

MASSACHUSETTS Safe Routes to School

# សុវត្ថិភាពជាចម្បង

## សម្រាប់អ្នកដំណើរជាសិស្សានុសិស្ស

massDOT Massachusetts Department of Transportation

MASSACHUSETTS Safe Routes to School

### កំពុងធ្វើដំណើរ



ជៀសវាងការប្រើប្រាស់ទូរសព្ទដៃរបស់អ្នក បើចាំបាច់ សូមប្រើមុខងារមិនចាំបាច់ប្រើដៃ។



កំណត់វិធានមូលដ្ឋានសម្រាប់ឥរិយាបថរបស់អ្នកដំណើរ ដើម្បីកាត់បន្ថយការរំខាន។



កុំបើកបរលឿនពេក ចំណាយពេលវេលាបន្តិច ដើម្បីជៀសវាងអារម្មណ៍ប្រញាប់ប្រញាល់។



សូមប្រុងប្រយ័ត្នចំពោះមនុស្សដើរ/ជិះកង់ ឡានក្រុង និងអ្នកដឹកនាំអ្នកដំណើរឆ្លងផ្លូវ នៅពេលចូលទៅជិតតំបន់សាលារៀន។

### ការស្វែងរកតំបន់ទម្លាក់/ទទួលសិស្សនៅសាលារៀន



ឈ្វេងយល់ដោយខ្លួនអ្នកអំពីនីតិវិធីមកដល់/ចេញពីសាលារៀនរបស់អ្នក។




អនុវត្តតាមការណែនាំពីអ្នកដឹកនាំអ្នកដំណើរឆ្លងផ្លូវ និងបុគ្គលិកសាលា។



សូមអត់ធ្មត់! សូមរង់ចាំរហូតដល់វេនរបស់អ្នក នៅពេលកំពុងតម្រង់ជួររថយន្តគ្រួសារ។



កុំចតឡានពីរជួរ ឬបត់ត្រឡប់ក្រោយ។



កុំចតឡានលើផ្លូវឆ្លងកាត់ ឬនៅជិតផ្លូវកាច់ជ្រុង។




គន្លងរថយន្តក្រុង គឺសម្រាប់តែរថយន្តក្រុង និងរថយន្តវែនប៉ុណ្ណោះ។

### ការដឹក និងដាក់អ្នកដំណើរចុះ



សូមអង្គុយតែកៅអីខាងក្រោយប៉ុណ្ណោះ! សិស្សថ្នាក់ទី Pk-8 មិនគួរនៅជិតពោងសុវត្ថិភាពទេ។




ប្រើតែកន្លែងដែលកំណត់ដោយសាលារៀនសម្រាប់ការឡើង/ចុះពីរថយន្តប៉ុណ្ណោះ។




ដាក់យានយន្តរបស់អ្នក “ចត” មុនពេលឡើង/ចុះពីរថយន្ត។




ត្រូវដាក់ខ្សែក្រវ៉ាត់សុវត្ថិភាព និងកៅអីរថយន្តមុនពេលយានយន្តរបស់អ្នកចាប់ផ្ដើមធ្វើដំណើរ និងក្រោយពេលដែលកាបូបស្ពាយត្រូវបានដកចេញ។



សូមប្រើតែផ្នែកអ្នកដំណើរខាងក្រោយនៃយានយន្តសម្រាប់សិស្សឡើង/ចុះពីរថយន្តប៉ុណ្ណោះ។



សូមកុំឆ្លងកាត់ផ្លូវ ឬផ្លូវចូលសាលារៀននៅពីមុខ ឬនៅចន្លោះយានយន្ត។

សូមមើលទំព័រអប់រំអ្នកបើកបរនៅលើគេហទំព័រ SRTS ដើម្បីទទួលបានធនធានពហុភាសាដែលមានប្រយោជន៍បន្ថែមទៀត រួមទាំង “សុវត្ថិភាពសិស្សក្នុងអំឡុងពេលបើកបរ” ផងដែរ។
ខិត្តប័ណ្ណសម្រាប់ការមកដល់ និងការចាកចេញពីផ្ទះ៖ www.mass.gov/lists/safe-routes-to-school-driver-education

ផ្លូវសុវត្ថិភាពទៅសាលារៀន (Safe Routes to School, SRTS) គឺជាកម្មវិធីដែលផ្តល់មូលនិធិដោយសហព័ន្ធ ដែលត្រូវបាន ផ្តល់ជូនដោយនាយកដ្ឋានដឹកជញ្ជូនរបស់រដ្ឋ Massachusetts។ កម្មវិធី SRTS ដំណើរការ ដើម្បីបង្កើនការដើរ ការជិះកង់ និងជិះក្តាររំអិលដោយសុវត្ថិភាពក្នុងចំណោមសិស្សសាលារដ្ឋថ្នាក់ទី K-12 ដោយប្រើវិធីសាស្ត្រដែលផ្តោតលើសហគមន៍ដែលមានលក្ខណៈសហការគ្នា ដែលដំណើរការឡើងដើម្បីបិទគម្លាតរវាងសុខភាព និងការដឹកជញ្ជូន។
ឈ្វេងយល់បន្ថែម៖ www.mass.gov/safe-routes-to-school